**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**លេខ: ៩០ អយក. ប្រក**

# ប្រកាស
## ស្តីពី
## បែបបទនិងនីតិវិធីនៃការវាយតម្លៃមត្តេយ្យសិក្សាសហគមន៍
## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៣/០១២ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា២៨ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញអនុក្រឹត្យលេខ ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ២៤៥ អនក្រ.បក ចុះថ្ងៃសុក្រ ១២កើត ខែបុស្ស ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីការគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍

## សម្រេច



អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២១០ ១៨៧ /២១៧ ២៥៣ /៤២៦ ៩៥១ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០/ ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / crsmeys@camnet.com.kh គេហទំព័រ : www.moeys.gov.kh

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**ប្រការ១ .-**

ប្រកាសនេះមានគោលបំណងកំណត់អំពីបែបបទ និងនីតិវិធីនៃការវាយតម្លៃមត្តេយ្យសិក្សាសហគមន៍ ផ្តល់ការទទួលស្គាល់ជាមត្តេយ្យសិក្សាសហគមន៍ដែលមានលក្ខណៈស្តង់ដា ដើម្បីទទួលបានថវិកាគាំទ្រពីក្រសួងអប់រំ យុវជន និងកីឡា។

**ប្រការ២ .-**

ប្រកាសនេះមានគោលដៅ៖

- កំណត់អំពីយន្តការ បែបបទ និងនីតិវិធីនៃការវាយតម្លៃមត្តេយ្យសិក្សាសហគមន៍ដែលមានលក្ខណៈស្តង់ដា
- ជំរុញមត្តេយ្យសិក្សាសហគមន៍នៅតាមរដ្ឋបាលឃុំ សង្កាត់ ឱ្យមានលក្ខណៈស្តង់ដា។

**ប្រការ៣ .-**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះមត្តេយ្យសិក្សាសហគមន៍ដែលមានលក្ខណៈស្តង់ដាស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋបាលឃុំ សង្កាត់។

## ជំពូកទី២
## គោលការណ៍ យន្តការ បែបបទ និងនីតិវិធីនៃការវាយតម្លៃមត្តេយ្យសិក្សាសហគមន៍
### ផ្នែកទី១
### គោលការណ៍ទូទៅ និងលក្ខណាវិនិច្ឆ័យ

**ប្រការ៤ .-**

ក្រសួងអប់រំ យុវជន និងកីឡា ត្រូវធ្វើការវាយតម្លៃមត្តេយ្យសិក្សាសហគមន៍ដែលមានលក្ខណៈស្តង់ដា ផ្អែកលើវឌ្ឍនភាពនៃមត្តេយ្យសិក្សាសហគមន៍ និងលទ្ធភាពថវិកា នៅរៀងរាល់ឆ្នាំសិក្សានីមួយៗ។

ដោយឡែកនៅឆ្នាំ២០១៨ ក្រសួងអប់រំ យុវជន និងកីឡា ត្រូវធ្វើការវាយតម្លៃយកមត្តេយ្យសិក្សាសហគមន៍ដែលមានលក្ខណៈស្តង់ដា ចំនួន ៦០០(ប្រាំមួយរយ)។

**ប្រការ៥ .-**

លក្ខណាវិនិច្ឆ័យនិងឧបករណ៍ស្ទង់វាយតម្លៃមត្តេយ្យសិក្សាសហគមន៍ ត្រូវអនុវត្តតាមឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ៦ .-**

មត្តេយ្យសិក្សាសហគមន៍ដែលទទួលបានការវាយតម្លៃហើយត្រូវបានប្រកាសថាជាមត្តេយ្យសិក្សាសហគមន៍ដែលមានលក្ខណៈស្តង់ដាដោយក្រសួងអប់រំ យុវជន និងកីឡា ត្រូវទទួលបានថវិកាគាំទ្រស្របតាមអនុក្រឹត្យលេខ ២៤៥ អនក្រ.បក ចុះថ្ងៃសុក្រ ១២កើត ខែបុស្ស ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីការគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន។

## ផ្នែកទី២
## យន្តការ បែបបទ និងនីតិវិធី

**ប្រការ៧ .-**

ការវាយតម្លៃមត្តេយ្យសិក្សាសហគមន៍ ត្រូវប្រើយន្តការរដ្ឋបាលឃុំ សង្កាត់ ការិយាល័យអប់រំ យុវជន និងកីឡា ក្រុង ស្រុក ខណ្ឌ មន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត និងក្រសួងអប់រំ យុវជន និងកីឡា ដោយផ្អែកលើលក្ខណវិនិច្ឆ័យនៃការវាយតម្លៃមត្តេយ្យសិក្សាសហគមន៍។

**ប្រការ៨ .-**

គណៈកម្មការគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍ ត្រូវធ្វើស្វ័យវាយតម្លៃលើមត្តេយ្យសិក្សាសហគមន៍ និងធ្វើការស្នើមកការិយាល័យអប់រំ យុវជន និងកីឡា ក្រុង ស្រុក ខណ្ឌ ដើម្បីសុំការវាយតម្លៃទទួលស្គាល់ជាមត្តេយ្យសិក្សាសហគមន៍ដែលមានលក្ខណៈស្តង់ដា ដោយការស្នើសុំនេះត្រូវមានៈ ពាក្យស្នើសុំ របាយការណ៍ស្វ័យវាយតម្លៃ បញ្ជីឈ្មោះសិស្ស ប្រវត្តិរូបគ្រូ បញ្ជីវត្តមានប្រជុំស្វ័យវាយតម្លៃរបស់គណៈកម្មការ និងបញ្ជីឈ្មោះគណៈកម្មការគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍។

**ប្រការ៩ .-**

ការិយាល័យអប់រំ យុវជន និងកីឡា ក្រុង ស្រុក ខណ្ឌ ត្រូវបង្កើតគណៈកម្មការវាយតម្លៃមត្តេយ្យសិក្សាសហគមន៍ ដែលមានសមាសភាព ដូចខាងក្រោម៖

| | |
|---|---|
| - អភិបាលរង ក្រុង ស្រុក ខណ្ឌ ទទួលបន្ទុក គ.ក.ស.ក | ប្រធាន |
| - ប្រធាន/អនុប្រធានការិយាល័យ អ.យ.ក ក្រុង ស្រុក ខណ្ឌ | អនុប្រធាន |
| - មន្ត្រីទទួលបន្ទុកអប់រំកុមារតូចនៃការិយាល័យ អ.យ.ក | សមាជិកអចិន្ត្រៃយ៍ |
| - មន្ត្រីទទួលបន្ទុកគណនេយ្យនៃការិយាល័យ អ.យ.ក | សមាជិក |
| - មន្ត្រីទទួលបន្ទុកបុគ្គលិកនៃការិយាល័យ អ.យ.ក | សមាជិក |
| - ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ គោលដៅ | សមាជិក |
| - តំណាងទទួលបន្ទុក គ.ក.ន.ក ក្នុងឃុំ សង្កាត់គោលដៅ | សមាជិក។ |

សមាសភាពជាក់ស្តែងនៃគណៈកម្មការនេះ ត្រូវកំណត់ដោយដីការបស់គណៈអភិបាល ក្រុង ស្រុក ខណ្ឌ។

គណៈកម្មការនេះ ត្រូវមានភារកិច្ចប្រជុំ និងចុះវាយតម្លៃដល់មត្តេយ្យសិក្សាសហគមន៍ ដោយផ្ទៀងផ្ទាត់លក្ខណវិនិច្ឆ័យនៃការវាយតម្លៃមត្តេយ្យសិក្សាសហគមន៍ រួចធ្វើរបាយការណ៍វាយតម្លៃបញ្ជូនទៅមន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត ដោយភ្ជាប់ឯកសារពាក់ព័ន្ធរួមមាន: សមាសភាពគណៈកម្មការវាយតម្លៃមត្តេយ្យសិក្សាសហគមន៍ បញ្ជីរាយឈ្មោះមត្តេយ្យសិក្សាសហគមន៍តាមចំណាត់ថ្នាក់ ឬលំដាប់ពិន្ទុ របាយការណ៍ប្រជុំវាយតម្លៃ និងបញ្ជីវត្តមានប្រជុំ។

**ប្រការ១០ .-**

មន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត ត្រូវធ្វើរបាយការណ៍បូកសរុបវាយតម្លៃ ផ្អែកលើលទ្ធផលនៃគណៈកម្មការវាយតម្លៃមត្តេយ្យសិក្សាសហគមន៍ថ្នាក់ក្រុង ស្រុក ខណ្ឌ រួចបញ្ជូនមកក្រសួងអប់រំ យុវជន និងកីឡា (នាយកដ្ឋានអប់រំកុមារតូច) ដោយភ្ជាប់ឯកសារពាក់ព័ន្ធរួមមាន: សមាសភាពគណៈកម្មការវាយតម្លៃមត្តេយ្យសិក្សាសហគមន៍ បញ្ជីរាយឈ្មោះមត្តេយ្យសិក្សាសហគមន៍តាមចំណាត់ថ្នាក់ ឬលំដាប់ពិន្ទុ របាយការណ៍ប្រជុំវាយតម្លៃ និងបញ្ជីវត្តមានប្រជុំ។

មន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត មានសិទ្ធិចុះត្រួតពិនិត្យការវាយតម្លៃរបស់គណៈកម្មការវាយតម្លៃមត្តេយ្យសិក្សាសហគមន៍ថ្នាក់ក្រុង ស្រុក ខណ្ឌ។

ករណីមានភាពមិនប្រក្រតីក្នុងការវាយតម្លៃរបស់គណៈកម្មការវាយតម្លៃមត្តេយ្យសិក្សាសហគមន៍ថ្នាក់ក្រុង ស្រុក ខណ្ឌ មន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត ត្រូវបង្កើតក្រុមការងារសម្រាប់ចុះពិនិត្យ និងវាយតម្លៃសាជាថ្មី។

**ប្រការ១១ .-**

ក្រសួងអប់រំ យុវជន និងកីឡា ត្រូវរៀបចំក្រុមការងារអន្តរក្រសួង ដែលមានសមាសភាពមកពីក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ និងក្រសួងមុខងារសាធារណៈ សម្រាប់វាយតម្លៃមត្តេយ្យសិក្សាសហគមន៍ ដើម្បីផ្តល់ការទទួលស្គាល់ជាមត្តេយ្យសិក្សាសហគមន៍ដែលមានលក្ខណៈស្តង់ដា។

ក្រសួងអប់រំ យុវជន និងកីឡា ត្រូវរៀបចំប្រកាសទទួលស្គាល់មត្តេយ្យសិក្សាសហគមន៍ដែលមានលក្ខណៈស្តង់ដា ផ្អែកលើលទ្ធផលរបស់ក្រុមការងារអន្តរក្រសួង ដែលបានវាយតម្លៃមត្តេយ្យសិក្សាសហគមន៍។

**ប្រការ១២ .-**

ក្រុមការងារអន្តរក្រសួងសម្រាប់វាយតម្លៃមត្តេយ្យសិក្សាសហគមន៍ មានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១. តំណាងក្រសួងអប់រំ យុវជន និងកីឡា | ចំនួន ០១រូប | ប្រធាន |
| ២. តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ចំនួន ០១រូប | អនុប្រធាន |
| ៣. តំណាងក្រសួងមហាផ្ទៃ | ចំនួន ០១រូប | អនុប្រធាន |
| ៤. តំណាងក្រសួងមុខងារសាធារណៈ | ចំនួន ០១ រូប | អនុប្រធាន |

៥. នាយកដ្ឋានអប់រំកុមារតូច សមាជិកអចិន្ត្រៃយ៍

៦. មន្ត្រីជំនាញរបស់ក្រសួង អ.យ.ក ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ និងក្រសួងមុខងារសាធារណៈ មួយចំនួនតាមការចាំបាច់ សមាជិក

សមាសភាពជាក់ស្តែងនៃក្រុមការងារនេះ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា។

**ប្រការ១៣ .-**

ក្រុមការងារអន្តរក្រសួងសម្រាប់វាយតម្លៃមត្តេយ្យសិក្សាសហគមន៍ មានភារកិច្ចដូចតទៅ៖

- ប្រមូលរបាយការណ៍វាយតម្លៃពីមន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត
- ប្រជុំពិនិត្យនិងសម្រេចលើបញ្ជីរាយឈ្មោះមត្តេយ្យសិក្សាសហគមន៍ដែលមានលក្ខណៈស្តង់ដា
- ចុះពិនិត្យនិងវាយតម្លៃដល់ទីតាំងមត្តេយ្យសិក្សាសហគមន៍ជាក់ស្តែង
- ធ្វើរបាយការណ៍ស្តីពីលទ្ធផលនៃការវាយតម្លៃជូនក្រសួងអប់រំ យុវជន និងកីឡា
- រៀបចំសេចក្តីព្រាងប្រកាសទទួលស្គាល់មត្តេយ្យសិក្សាសហគមន៍ដែលមានលក្ខណៈស្តង់ដា ជូនក្រសួងអប់រំ យុវជន និងកីឡា ពិនិត្យនិងសម្រេច
- ផ្តល់អនុសាសន៍ និងដំណោះស្រាយពាក់ព័ន្ធនឹងការវាយតម្លៃមត្តេយ្យសិក្សាសហគមន៍ជូនក្រសួងអប់រំ យុវជន និងកីឡា
- បំពេញភារកិច្ចផ្សេងទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

**ប្រការ១៤ .-**

មត្តេយ្យសិក្សាសហគមន៍ ដែលត្រូវបានទទួលស្គាល់ជាមត្តេយ្យសិក្សាសហគមន៍ដែលមានលក្ខណៈស្តង់ដា នឹងត្រូវធ្វើការវាយតម្លៃម្តងទៀត នៅរៀងរាល់០៣(បី)ឆ្នាំម្តង ដើម្បីទទួលថវិកាគាំទ្រពីក្រសួងអប់រំ យុវជន និងកីឡា បន្តទៀត។ ករណីមត្តេយ្យសិក្សាសហគមន៍ដែលពុំជាប់ស្តង់ដាពេញលេញក្នុងរយៈពេល ០៣(បី)ឆ្នាំនេះ មិនទទួលបានថវិកាគាំទ្រពីក្រសួងអប់រំ យុវជន និងកីឡាឡើយ។

## ជំពូកទី៣

## អវសានប្បញ្ញត្តិ

**ប្រការ១៥ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១៦ .-**

អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំ អគ្គនាយកនៃអគ្គនាយកដ្ឋានគោលនយោបាយនិងផែនការ អគ្គនាយកនៃអគ្គនាយកដ្ឋានឧត្តមសិក្សា អគ្គនាយកនៃអគ្គនាយកដ្ឋានយុវជន អគ្គនាយកនៃអគ្គនាយកដ្ឋានកីឡា អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋាន

អប់រំកុមារតូច ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ និងប្រធានគ្រប់អង្គភាពដែលពាក់ព័ន្ធរបស់ក្រសួងអប់រំ យុវជន និងកីឡា ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ព្រហ. ២ កើត ខែ ចេត្រ ឆ្នាំរកា នព្វស័ក ព.ស ២៥៦១

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ២០១៨

បណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ក្រសួងមុខងារសាធារណៈ
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

"ដើម្បីជូនជ្រាប"

- គ្រប់អង្គភាពក្រោមឱវាទក្រសួង អ.យ.ក
- មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត
- ដូចប្រការ១៦

"ដើម្បីអនុវត្ត"

- ឯកសារ កាលប្បវត្តិ នា.នីតិកម្ម